# ជំនួយសម្រាប់អ្នកបោះឆ្នោត

*មានវិធីជាច្រើនសម្រាប់អ្នកបោះឆ្នោតដែលមានពិការភាពជាច្រើនដើម្បីបោះឆ្នោតជាលក្ខណៈឯកជន និងដោយឯករាជ្យ។*

## *ភាពងាយស្រួលចេញចូលមណ្ឌលបោះឆ្នោត*

ច្បាប់រដ្ឋ និងច្បាប់សហព័ន្ធតម្រូវឱ្យផ្តល់ភាពងាយស្រួលចេញចូលមណ្ឌលបោះឆ្នោត។ ជាទូទៅ ទីក្រុង និងទីប្រជុំជនជ្រើសរើសទីតាំងមណ្ឌលបោះឆ្នោត ហើយទទួលខុសត្រូវក្នុងការផ្តល់ភាពងាយស្រួលចេញចូលមណ្ឌលបោះឆ្នោត។

### *កាលបរិច្ឆេទឆ្នាំ 2026*

***បោះឆ្នោតមុនកាលកំណត់***
*ថ្ងៃទី 26 ខែមិថុនា - ថ្ងៃទី 10 ខែសីហា*

***ចុះឈ្មោះជាមុន***
*ត្រឹមថ្ងៃទី 21 ខែកក្កដា*

***ការបោះឆ្នោតបឋម***
*ថ្ងៃអង្គារ ទី 11 ខែសីហា*

***បោះឆ្នោតមុនកាលកំណត់***
*ថ្ងៃទី 18 ខែកញ្ញា - ថ្ងៃទី 2 ខែវិច្ឆិកា*

***ចុះឈ្មោះជាមុន***
*ត្រឹមថ្ងៃទី 13 ខែតុលា*

***ថ្ងៃបោះឆ្នោត***
*ថ្ងៃអង្គារ ទី 3 ខែវិច្ឆិកា*

## *ជំនួយពីអ្នកដទៃ*

អ្នកអាចនាំអ្នកណាម្នាក់មកជួយអ្នកនៅពេលអ្នកបោះឆ្នោត ឬអ្នកអាចទទួលបានជំនួយពីថៅក្រមបោះឆ្នោត ។ អ្នកមិនអាចទទួលបានជំនួយពីនិយោជក ឬសហជីពរបស់អ្នកបានទេ។ ជំនួយការរបស់អ្នកអាចចូលរួមក្នុងគ្រប់ផ្នែកទាំងអស់នៃដំណើរការបោះឆ្នោត។ ជំនួយការមិនអាចជះឥទ្ធិពលលើរបៀបដែលអ្នកបោះឆ្នោត ឬគូសសន្លឹកឆ្នោតជំនួសអ្នកបានទេ ប្រសិនបើអ្នកមិនអាចប្រាប់ទៅពួកគេអំពីអ្នកដែលអ្នកចង់បោះឆ្នោតឱ្យ។

## *ចុះហត្ថលេខាផ្ទាល់មាត់*

អ្នកមានសិទ្ធិបញ្ជាក់ផ្ទាល់មាត់ថាអ្នកជានរណា និងស្នើសុំឱ្យអ្នកដទៃចុះហត្ថលេខាជំនួសអ្នក ប្រសិនបើអ្នកមិនអាចចុះហត្ថលេខាលើឈ្មោះរបស់អ្នកបាន។

## *អ្នកបោះឆ្នោតក្រោមអាណាព្យាបាលភាព*

អ្នកអាចបោះឆ្នោតពេលស្ថិតនៅក្រោមអាណាព្យាបាលភាពបាន លុះត្រាតែថៅក្រមបានដកហូតជាក់ស្តែងនូវសិទ្ធិបោះឆ្នោតរបស់អ្នកនៅក្នុងដីការបស់តុលាការ។

*បន្តនៅទំព័រក្រោយ...*

# ជំនួយសម្រាប់អ្នកបោះឆ្នោត

VOTE 2026

*...បន្តពីទំព័រមុខ*

## *ម៉ាស៊ីនបោះឆ្នោតសម្រាប់ជនមានពិការភាព*

មណ្ឌលបោះឆ្នោតមានម៉ាស៊ីនដែលអាចគូសសន្លឹកឆ្នោតជំនួសអ្នកបាន។ ម៉ាស៊ីននេះផ្តល់ឱ្យអ្នកនូវឯកជនភាព ប្រសិនបើអ្នកមិនអាច (ឬជ្រើសរើសមិន) បោះឆ្នោតដោយប្រើប៊ិក។ ម៉ាស៊ីននេះមានអេក្រង់ដែលបង្ហាញសន្លឹកឆ្នោតជាអក្សរពុម្ពធំ ឬមានផ្ទៃខាងក្រោយដែលមានកម្រិតពណ៌ខ្ពស់។ ម៉ាស៊ីននេះក៏អាចអានសន្លឹកឆ្នោតឱ្យអ្នកស្តាប់តាមរយៈកាសស្តាប់ត្រចៀកផងដែរ។ អ្នកអាចបំពេញសន្លឹកឆ្នោតរបស់អ្នកដោយប្រើគ្រាប់ចុចអក្សរស្ទាប អេក្រង់ប៉ះ ឬឧបករណ៍ផ្លុំ។ បន្ទាប់ពីអ្នកធ្វើការជ្រើសរើសហើយ ម៉ាស៊ីននឹងបោះពុម្ពសន្លឹកឆ្នោតដែលអ្នកបានបំពេញរួច។

## *ការបោះឆ្នោតនៅក្រៅមណ្ឌល*

ប្រសិនបើអ្នកមិនអាចចេញពីរថយន្តរបស់អ្នកបានដោយងាយស្រួលបានទេ អ្នកអាចស្នើសុំឱ្យគេយកសន្លឹកឆ្នោតចេញមកក្រៅឱ្យអ្នក។ នេះគេហៅថា 'ការបោះឆ្នោតនៅក្រៅមណ្ឌល'។ ចៅក្រមបោះឆ្នោតពីររូបមកពីគណបក្សនយោបាយធំៗផ្សេងៗគ្នានឹងយកសន្លឹកឆ្នោតចេញមកក្រៅឱ្យអ្នក។ នៅពេលអ្នកបោះឆ្នោតរួចរាល់ ចៅក្រមបោះឆ្នោតនឹងយកសន្លឹកឆ្នោតរបស់អ្នកមកខាងក្នុង ហើយដាក់វានៅក្នុងប្រអប់សន្លឹកឆ្នោត។

## *ទទួលបានសន្លឹកឆ្នោតថ្មី*

អ្នកមានសិទ្ធិទទួលបានសន្លឹកឆ្នោតថ្មី ប្រសិនបើអ្នកគូសខុសលើសន្លឹកឆ្នោតរបស់អ្នកមុនពេលអ្នកបោះ។

## *ដាក់ពាក្យបណ្តឹង*

អ្នកមានសិទ្ធិដាក់ពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរនៅមណ្ឌលបោះឆ្នោតរបស់អ្នក ប្រសិនបើអ្នកមិនពេញចិត្តនឹងរបៀបដែលការបោះឆ្នោតកំពុងត្រូវបានដំណើរការ។

*ស្កេនលេខកូដនេះដើម្បីចូលទៅកាន់វិបសាយ*
*mnvotes.gov*
*និងចុះឈ្មោះបោះឆ្នោត!*